ក N°52/16→*15/7/2016*

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៤-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៦៦ ស្តីពី ការតែងតាំងអនុប្រធានប្រចាំការ សមាជិក នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ និងតែងតាំងទីប្រឹក្សាជាន់ខ្ពស់ និងទីប្រឹក្សានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ បន្ថែម លើមុខតំណែងបច្ចុប្បន្ន ចំនួន ១៧ រូប ៦០៤៩

២៤-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៦៧ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **គិន ឆេងលី** ពីទីប្រឹក្សាក្រសួងមហាផ្ទៃ ឋានៈស្មើអនុរដ្ឋលេខាធិការ ៦០៥១

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៦៨ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ចាន់ រ៉ាស៊ី** ពីអគ្គលេខាធិការ នៃក្រុមប្រឹក្សាធម្មនុញ្ញ និងតែងតាំងឯកឧត្តម **ម៉េង គឹមលី** ជាអគ្គលេខាធិការ នៃក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ រដ្ឋលេខាធិការ ៦០៥២

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៦៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២០ រូប ៦០៥៣

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៧០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ដល់ឧត្តមសេនីយ៍ទោ **ជឹម តើយ** នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៦០៥៥

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៧១ ស្តីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិ ដល់មន្ត្រីពន្ធនាគារ ចំនួន ០៦ រូប នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៦០៥៦

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៧២ ស្តីពី ការតែងតាំងអស់លោក ចំនួន ៣ រូប ជាឧកញ៉ា ៦០៥៨

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៧៣ ស្តីពី ការតែងតាំងឯកឧត្តម **ចាន់ រ៉ាស៊ី** ជាជាអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ៦០៥៩

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៧៤ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ឈាន ហៀង** ជាទីប្រឹក្សាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ អគ្គនាយក ៦០៦០

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៧៥ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ហែម សារេត** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៦០៦១

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៧៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈទីប្រឹក្សាអមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ១២ រូប ៦០៦២

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៧៧ ស្តីពី ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ដោយគ្មានការបង្ខិតបង្ខំ ដល់កញ្ញា **សុខ សាណារ៉ា** (SOK SANARA) ជនជាតិខ្មែរ សញ្ជាតិខ្មែរ បច្ចុប្បន្នកំពុងរស់នៅប្រទេសហូឡង់ ៦០៦៤


## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ


០៦-៧-២០១៦ -អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ស្តីពី ការផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ ៦០៦៥

០៧-៧-២០១៦ -អនុក្រឹត្យលេខ ១៣៨ អនក្រ.បក ស្តីពី ការកែសម្រួលអនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី ការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ៦០៦៩

០១-៧-២០១៦ -អនុក្រឹត្យលេខ ៧៣៨ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៦០៧១

០១-៧-២០១៦ -អនុក្រឹត្យលេខ ៧៣៩ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៦០៧២

០១-៧-២០១៦ -អនុក្រឹត្យលេខ ៧៤០ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៦០៧៤

០១-៧-២០១៦ -អនុក្រឹត្យលេខ ៧៤១ អនក្រ.តត ស្តីពី ការដាក់ឱ្យចូលនិវត្តន៍មន្ត្រីនគរបាលជាតិកម្ពុជា ៦០៧៥

០១-៧-២០១៦ -អនុក្រឹត្យលេខ ៧៤២ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៦០៧៧

០១-៧-២០១៦ -អនុក្រឹត្យលេខ ៧៤៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៦០៧៨

*-អនុក្រឹត្យលេខ ៧៤៤ អនក្រ.តត មិនទាន់បានទទួល*

០១-៧-២០១៦ -អនុក្រឹត្យលេខ ៧៤៥ អនក្រ.តត ស្តីពី ការតែងតាំងផ្លាស់ប្តូរមុខងារ នាយទាហាន ៦០៨០

០១-៧-២០១៦ -អនុក្រឹត្យលេខ ៧៤៦ អនក្រ.តត ស្តីពី ការផ្ទេរយោធិនពលី មរណៈ ៦០៨១

០១-៧-២០១៦ -អនុក្រឹត្យលេខ ៧៤៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦០៨៤

០៤-៧-២០១៦ -អនុក្រឹត្យលេខ ៧៤៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦០៨៥
០៤-៧-២០១៦ -អនុក្រឹត្យលេខ ៧៤៩ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មថ្នាក់មន្ត្រីរាជការ ៦០៨៧
០៤-៧-២០១៦ -អនុក្រឹត្យលេខ ៧៥០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦០៨៩
០៤-៧-២០១៦ -អនុក្រឹត្យលេខ ៧៥១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦០៩០

## III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៤-៥-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៥៤៧ សហវ.ប្រក ស្តីពី ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន របស់ក្រសួងអប់រំ យុវជន និងកីឡា នៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ៦០៩១
០៦-៥-២០១៦ -ប្រកាសលេខ ៥៦០ សហវ.ប្រក ស្តីពី ការទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការឱ្យចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៦០៩៣
១២-៥-២០១៦ -ប្រកាសលេខ ៥៧០ សហវ.ប្រក ស្តីពី ការបង្កើតរដ្ឋទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់គណៈកម្មការមូលបត្រកម្ពុជា ៦០៩៥
១៦-៥-២០១៦ -ប្រកាសរួមលេខ ៥៧៦ សហវ.ប្រក ស្តីពី ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ៦១០១
១៦-៥-២០១៦ -ប្រកាសរួមលេខ ៥៧៧ សហវ.ប្រក ស្តីពី ការគ្រប់គ្រង និងការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីការបង្ក្រាបបទល្មើសគ្រឿងញៀន ៦១០៨
២៥-៥-២០១៦ -ប្រកាសរួមលេខ ៦១៧ សហវ.ប្រក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគ្រឹះស្ថានអង្គរ ៦១១៣
២៧-៥-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៦១៩ សហវ.ប្រក ស្តីពី ការបង្កើតរដ្ឋទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៦១២០
២៧-៥-២០១៦ -សេចក្តីសម្រេចលេខ ០២៩ សហវ ស្តីពី ការបង្កើតអនុគណៈកម្មការដេញថ្លៃលក់ឈើ និងកូនឈើ ដែលគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន ៦១២៤
៣០-៥-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៦១៨ សហវ.ប្រក ស្តីពី ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន របស់ក្រសួងអប់រំ យុវជន និងកីឡា នៅនាយកដ្ឋានហិរញ្ញវត្ថុ ៦១២៨

៣១-៥-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៦២៤ សហវ.ប្រក ស្តីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់សាកលវិទ្យាល័យមានជ័យ ៦១៣០

០៦-៦-២០១៦ -ប្រកាសរួមលេខ ៦៥៩ សហវ.ប្រក ស្តីពី ការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ ៦១៣៥

១០-៦-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៦៧៧ សហវ.ប្រក ស្តីពី ការដាក់ឱ្យអនុវត្តអង្គភាពថវិកា រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៦១៥៣

២០-៦-២០១៦ -ប្រកាសលេខ ៧២៥ សហវ.ប្រក ស្តីពី ការអនុញ្ញាតឱ្យមន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ៦១៦៤

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

២១-៦-២០១៦ -ប្រកាសលេខ ២៣៨ កប/ប្រក ស្តីពី ការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ៦១៦៦

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៣៦៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងអនុប្រធានប្រចាំការ និងសមាជិកនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ បន្ថែមលើមុខតំណែងបច្ចុប្បន្ន ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ច័ន្ទ មេត្តាពល** | សមាជិកគណៈកម្មការភាសាវិទ្យាខ្មែរនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធានប្រចាំការ មានឋានៈស្មើរដ្ឋលេខាធិការ | |
| ២- ឯកឧត្តមបណ្ឌិត **ខាង ពៅ** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៣- ឯកឧត្តមបណ្ឌិត **សឹង រេត** | ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

| | | | |
|---|---|---|---|
| ៤- ឯកឧត្តមបណ្ឌិត **ឡឹក បូផា** | ទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា | | ជាសមាជិក |
| ៥- ឯកឧត្តម **ហាក់ សឹងលី** | ទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា | | ជាសមាជិក |
| ៦- ឯកឧត្តម **ហ៊ីង គីមថន** | ទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា | | ជាសមាជិក |
| ៧- ឯកឧត្តម **ស៊ឹម សៀងប៉ាង** | ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា | | ជាសមាជិក |
| ៨- ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ម សំ** | | **អត្តលេខ ០០២៥១២** | ជាសមាជិក |
| ៩- ឯកឧត្តមឧត្តមសេនីយ៍ទោ **អឿ សាម៉ន** | | **អត្តលេខ ០០៩៤៧៥** | ជាសមាជិក |
| ១០- លោក **ឡាក់ ឡេង** | | | ជាសមាជិក |
| ១១- លោក **ហ៊ៅ គីមី** | | | ជាសមាជិក |
| ១២- លោកស្រី **ហង់ ថាវី** | | | ជាសមាជិក |
| ១៣- លោក **ហេង នីវ៉ាដូ** | | | ជាសមាជិក |

**មាត្រា២ :** តែងតាំងទីប្រឹក្សាជាន់ខ្ពស់ និងទីប្រឹក្សានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ បន្ថែមលើមុខតំណែងបច្ចុប្បន្ន៖

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ិន សំណាង** | ទីប្រឹក្សារាជរដ្ឋាភិបាល | ជាទីប្រឹក្សាជាន់ខ្ពស់ |
| ២- លោកជំទាវ **ហ៊ៅ សុជាតិយ** | | ជាទីប្រឹក្សាជាន់ខ្ពស់ |
| ៣- ព្រះមង្គលបញ្ញា **សៅរ៍ តារាទី** | ព្រះរាជាគណៈ ថ្នាក់កិត្តិយស | ជាទីប្រឹក្សា |
| ៤- ព្រះបវរមុនី **ឈិត សុផៃ** | ព្រះរាជាគណៈថ្នាក់កិត្តិយស | ជាទីប្រឹក្សា |

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៦១៦.៦៧៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ: ៦៤៥ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៦៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** បញ្ចប់មុខតំណែងឯកឧត្តម **គិន ឆេងលី** ពីទីប្រឹក្សាក្រសួងមហាផ្ទៃ ឋានៈស្មើអនុរដ្ឋលេខាធិការ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៦០៦.៦៧៤

លេខៈ ៦៥២ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៦៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ៣ឆ្នាំ លើកទី៧
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** បញ្ចប់មុខតំណែងឯកឧត្តម **ចាន់ រ៉ាស៊ី** ពីអគ្គលេខាធិការ នៃក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា២ :** តែងតាំងឯកឧត្តម **ម៉េង គីមលី** ជាអគ្គលេខាធិការ នៃក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា៣ :** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ៧. ១៦០៦. ៦៧៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

លេខៈ ៧០៤ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៦១៦/៦៦៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ឯក | **ស៊ិន ឆ៉ាត** | អត្តលេខ | ០៦៧៣៨ |
| ២- | វរសេនីយ៍ឯក | **ម៉ុល រិទ្ធិ** | អត្តលេខ | ២០៣៧៨ |
| ៣- | វរសេនីយ៍ឯក | **សោម សំណាង** | អត្តលេខ | ០៥២៦៨ |
| ៤- | វរសេនីយ៍ឯក | **ហ៊ុន សំណាង** | អត្តលេខ | ៥៨១១៤ |
| ៥- | វរសេនីយ៍ឯក | **ស៊ឹង យុត្តា** | អត្តលេខ | ០៩៦៨០ |
| ៦- | វរសេនីយ៍ឯក | **គៀន សាន** | អត្តលេខ | ៦២៧៩៧ |
| ៧- | វរសេនីយ៍ឯក | **អ៊ឹម ដារិទ្ធ** | អត្តលេខ | ០៤៧៨៧ |
| ៨- | វរសេនីយ៍ឯក | **អ៊ិច ឆុង្សី** | អត្តលេខ | ៦១៧៣៦ |
| ៩- | វរសេនីយ៍ឯក | **ពុទ្ធ សៅស៊ីវ៉ាណា** | អត្តលេខ | ០៥៤៧៦ |
| ១០- | វរសេនីយ៍ឯក | **អ៊ុយ ផល្លី** | អត្តលេខ | ១៦១៨៨ |
| ១១- | វរសេនីយ៍ឯក | **ខួន ម៉ុង** | អត្តលេខ | ០៥០៨២ |

| | | | | |
|---|---|---|---|---|
| ១២- | វរសេនីយ៍ឯក | **សន សារឿន** | អត្តលេខ | ០១០៦៩ |
| ១៣- | វរសេនីយ៍ឯក | **ប៉ែន សុផ៉ាត់ឌី** | អត្តលេខ | ៦១៦៧២ |
| ១៤- | វរសេនីយ៍ឯក | **គុខ គឹមផុខ** | អត្តលេខ | ៣១៦៣២ |
| ១៥- | វរសេនីយ៍ឯក | **ឯម បាណារ៉ាន** | អត្តលេខ | ០៨៤៦២ |
| ១៦- | វរសេនីយ៍ឯក | **សឿង ណុល** | អត្តលេខ | ១៥៧៦៧ |
| ១៧- | វរសេនីយ៍ឯក | **រស់ សំបូរ** | អត្តលេខ | ០៦៤៤៧ |
| ១៨- | វរសេនីយ៍ឯក | **ឆន ឡាឌី** | អត្តលេខ | ៥៦៣៤៧ |
| ១៩- | វរសេនីយ៍ឯក | **ម៉ាំង សំរ៉ែង** | អត្តលេខ | ០១០៥១ |
| ២០- | វរសេនីយ៍ឯក | **សុទ្ធ សំអាន** | អត្តលេខ | ០១៣៧៤ ។ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៦១៦.៦៧៦

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦

លេខ: ៦៧៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ដល់ឧត្តមសេនីយ៍ទោ **ជឹម តើយ** អត្តលេខ ០០០៤០១ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦

ការ. ១៦០៦.៦៧៧

លេខ: ៦៧០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៦១៦/៦៧១

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី**
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងថ្នាក់ និង ឋានន្តរស័ក្តិ ដល់មន្ត្រីពន្ធនាគារ ចំនួន ០៦រូប នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៖

១- លោក **ខាត់ សារ៉ាន់** ពីឋានន្តរស័ក្តិឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣ មកឋានន្តរស័ក្តិឧត្តមអគ្គានុរក្ស ថ្នាក់លេខ ២ អត្តលេខ ០០៨៤

២- លោក **សន គែម** ពីឋានន្តរស័ក្តិឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣ មកឋានន្តរស័ក្តិឧត្តមអគ្គានុរក្ស ថ្នាក់លេខ ២ អត្តលេខ ០០១៧

៣- លោក **អ៊ុច ពន្ស** ពីឋានន្តរស័ក្តិឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣ មកឋានន្តរស័ក្តិឧត្តមអគ្គានុរក្ស ថ្នាក់លេខ ២ អត្តលេខ ០០៤១

៤- លោក **អ៊ុក គីមឌន** ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ ១ មកឋានន្តរស័ក្តិឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣ អត្តលេខ ០១៦៧

៥- លោក **គែម នន់** ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ ១ មកឋានន្តរស័ក្តិឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣ អត្តលេខ ០០៨៥

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

៦- លោក **កែ ម៉ុនឃ្មុះ** ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ ១ មកឋានន្តរស័ក្តិឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣ អត្តលេខ ០១៨១។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត.០៦១៦.៦៧៨

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

លេខៈ៦៧៧ ស.ណ

សំណៅចែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

នស/រកត/០៦១៦/៦៧៤

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ត្រាស់បង្គាប់**

**តែងតាំង :**

១- លោក **ចាន់ ស៊ីថា**
២- លោក **មិល សារឿន**
៣- លោកវេជ្ជបណ្ឌិត **សេង បញ្ញាឫទ្ធិ**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៦០៦.៦៧៩

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ: ៦៧៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៦១៦/៦៧៣

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស /រកម / ០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ចាន់ រ៉ាស៊ី** ជាអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៨៧.១៦០៦.៦៤០

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦

លេខ: ៦៧១ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៧៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស /រកម / ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈ ឯកឧត្តម **ឈាន ហឿង** ជាទីប្រឹក្សាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរា. ១៦០៦.៦៨១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ: ៦៧២ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/ ៦៧៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈ ឯកឧត្តម **ហែម សារេត** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរម. ១៦០៦.៦៨២

លេខ: ៦៧៤ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៧៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈ ទីប្រឹក្សាអមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ១២ រូបៈ

១-ឯកឧត្តម **យឹម ឈុន** ទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយក**
២-ឯកឧត្តម **ហេង ម៉ិនឈុន** ទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយក**
៣-ឯកឧត្តម **សាត់ ឈាងហួ** ទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយក**
៤-ឯកឧត្តម **តុល ផាន់ម៉ឿង** ទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយក**
៥-ឯកឧត្តម **មុំ សារ៉ែន** ទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយក**
៦-ឯកឧត្តម **ជុំ ម៉ឺត** ទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយក**
៧-ឯកឧត្តម **គីម ចាន់សំណាង** ទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយក**
៨-ឯកឧត្តម **វ៉ាត សំណាង** ទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយក**
៩-ឯកឧត្តម **ឈុំ វាសនា** ទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយក**
១០-ឯកឧត្តម **សួង ហួត** ទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយក**

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

១១-ឯកឧត្តម **លាង ស៊ុនហ៊ាង** ទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយក**

១២-ឯកឧត្តម **ហែម សុខពន្លក** ទីប្រឹក្សាអមក្រសួង មានឋានៈស្មើ **អគ្គនាយក**

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស. ១៦០៦. ៦៨៣

លេខ: ៦៧៥ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

**សំណៅចែងមានអង្គេជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៧៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** អនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ដោយគ្មានការបង្ខិតបង្ខំ ដល់កញ្ញា សុខ សាណារា( SOK SANARA ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៣ ទីកន្លែងកំណើត ភូមិចំការហ្លួង ឃុំវាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ បច្ចុប្បន្នកំពុងរស់នៅប្រទេសហូឡង់។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរជ.១៦០៦.៦៩៤

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ: ៦៦៩ ស.ណ
សំណៅចែដលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែ ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែទូទាំងប្រទេស ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅ៖

- សម្រិតសម្រាំងសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ
- លើកទឹកចិត្តសិស្សនៅមធ្យមសិក្សាឱ្យផ្តោតការយកចិត្តទុកដាក់លើអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ
- ផ្តល់តម្លៃដល់ជ័យលាភីសិស្សពូកែ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជ័យលាភីសិស្សពូកែទូទាំងប្រទេសនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈនិងឯកជនថ្នាក់ទី៩និងថ្នាក់ទី១២។

## ជំពូកទី២
## ការប្រឡងជ្រើសរើសសិស្សពូកែ

**មាត្រា៤ .-**

ការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្តផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ ថ្នាក់ទី៩ និងថ្នាក់ទី១២ ត្រូវរៀបចំឡើងដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ ថ្នាក់ទី៩ និងថ្នាក់ទី១២ត្រូវរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥ .-**

យន្តការនិងនីតិវិធីនៃការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្តថ្នាក់ទី៩ និងថ្នាក់ទី១២ និងយន្តការនិងនីតិវិធីនៃការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសថ្នាក់ទី៩និងថ្នាក់ទី១២ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦ .-**

ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសថ្នាក់ទី៩និងថ្នាក់ទី១២ ត្រូវប្រព្រឹត្តទៅនៅរាជធានីភ្នំពេញឬទីរួមខេត្តណាមួយ ទាំងដំណើរការសំណេរ កំណែ ស្រង់ បូកពិន្ទុនិងប្រកាសលទ្ធផលប្រឡង។

វិញ្ញាសាប្រឡងត្រូវចេញដោយក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកលើកម្មវិធីសិក្សាចាប់ពីថ្នាក់ទី៧ដល់ថ្នាក់ទី៩ សម្រាប់ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសថ្នាក់ទី៩ និងផ្អែកលើកម្មវិធីសិក្សាចាប់ពីថ្នាក់ទី៧ដល់ថ្នាក់ទី១២ សម្រាប់ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសថ្នាក់ទី១២។

**មាត្រា៧ .-**

ក្នុងការប្រឡងជ្រើសរើសសិស្សពូកែតាមឆ្នាំសិក្សានីមួយៗ បេក្ខជនម្នាក់ៗមានសិទ្ធិជ្រើសរើសបានតែមួយមុខវិជ្ជាគត់ក្នុងចំណោមមុខវិជ្ជាទាំងបី។

**មាត្រា៨ .-**

គណៈមេប្រយោគប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ត្រូវបំពេញការងារតាមចំនួនថ្ងៃជាក់ស្តែង និងទទួលប្រាក់ឧបត្ថម្ភតាមរបបម៉ោងបន្ថែមដោយគិតក្នុងមួយថ្ងៃបំពេញការងារ៦(ប្រាំមួយ)ម៉ោងបន្ថែម ហើយប្រាក់កំរៃមួយម៉ោងបន្ថែមស្មើប្រាក់កម្រៃនៃមួយម៉ោងបន្ថែមរបស់គ្រូមធ្យមសិក្សាទុតិយភូមិ។

ការចាត់តាំងគណៈមេប្រយោគ និងគណៈកម្មការផ្សេងៗសម្រាប់ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ជាសមត្ថកិច្ចរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៩ .-**

ថវិកាប្រឡងសម្រាប់ចំណាយលើសម្ភារៈចាំបាច់ផ្សេងៗ ការរៀបចំពិធីបើកការប្រឡង និងពិធីចែករង្វាន់ សោហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុករបស់ប្រតិភូរាជធានី ខេត្ត និងបេក្ខជន និងចំណាយសម្រាប់រៀបចំដំណើរកម្សាន្តរបស់បេក្ខជន ជាបន្ទុករបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៣

## រង្វាន់និងការលើកទឹកចិត្ត

**មាត្រា១០ .-**

ជ័យលាភីសិស្សពូកែទូទាំងប្រទេស ត្រូវទទួលបានរង្វាន់និងការលើកទឹកចិត្តពីរាជរដ្ឋាភិបាលដូចខាងក្រោម៖

១. ប្រកាសស្តីពីការទទួលស្គាល់សិស្សពូកែ ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មួយច្បាប់

២. មេដាយមួយគ្រឿង សម្រាប់បេក្ខជនជ័យលាភីចំណាត់ថ្នាក់ពីលេខ១ដល់លេខ៣

៣. វិញ្ញាបនបត្របញ្ជាក់សិស្សពូកែទូទាំងប្រទេស មួយច្បាប់

៤. ប្រាក់រង្វាន់តាមចំណាត់ថ្នាក់៖

- ចំណាត់ថ្នាក់លេខ១ ៣ ៥០០ ០០០ (បីលានប្រាំសែន)រៀល
- ចំណាត់ថ្នាក់លេខ២ ៣ ២០០ ០០០ (បីលានពីរសែន)រៀល
- ចំណាត់ថ្នាក់លេខ៣ ២ ៩០០ ០០០ (ពីរលានប្រាំបួនសែន)រៀល
- ចំណាត់ថ្នាក់លេខ៤ ២ ៦០០ ០០០ (ពីរលានប្រាំមួយសែន)រៀល
- ចំណាត់ថ្នាក់លេខ៥ ២ ៣០០ ០០០ (ពីរលានបីសែន)រៀល
- ចំណាត់ថ្នាក់លេខ៦ ២ ០០០ ០០០ (ពីរលាន)រៀល
- ចំណាត់ថ្នាក់លេខ៧ ១ ៧០០ ០០០ (មួយលានប្រាំពីរសែន)រៀល
- ចំណាត់ថ្នាក់លេខ៨ ១ ៤០០ ០០០ (មួយលានបួនសែន)រៀល
- ចំណាត់ថ្នាក់លេខ៩ ១ ១០០ ០០០ (មួយលានមួយសែន)រៀល
- ចំណាត់ថ្នាក់លេខ១០ ៨០០ ០០០ (ប្រាំបីសែន)រៀល

បុគ្គល បុព្វជិត គ្រួសារ សហគមន៍ សង្គមស៊ីវិល ស្ថាប័នរដ្ឋនិងឯកជនទាំងអស់ មានសិទ្ធិផ្តល់រង្វាន់ជាសម្ភារៈ ឬថវិកាជូនជ័យលាភីសិស្សពូកែ។

**មាត្រា១១ .-**

ក្រសួងអប់រំ យុវជន និងកីឡាមានភារកិច្ចរៀបចំពីធីបើកការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស និងរៀបចំពីធីចែករង្វាន់ដល់ជ័យលាភីសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ ឱ្យបានសមរម្យ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

អនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៣៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលអនុក្រឹត្យលេខ ៤២ អនក្រ.បក
# ស្តីពី
# ការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែ មករា ឆ្នាំ២០០៧

-ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

-យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**មាត្រា ១** : មាត្រា២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានកែប្រែដូចតទៅៈ

**មាត្រា២ថ្មី**: អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញដឹកនាំដោយអគ្គលេខាធិការមួយរូប អគ្គលេខាធិការរងមួយចំនួនជាអ្នកជំនួយការ នៅក្រោមការទទួលខុសត្រូវរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ អគ្គលេខាធិការដឹកនាំបញ្ជាការងាររដ្ឋបាលរបស់

ក្រុមប្រឹក្សាធម្មនុញ្ញ។ អគ្គលេខាធិការអាចទទួលសិទ្ធិពីប្រធានដើម្បីចុះហត្ថលេខាលើលិខិតឬសេចក្តីសម្រេចរដ្ឋបាល។ អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីជាន់ខ្ពស់មានបទពិសោធន៍ក្នុងកិច្ចការរដ្ឋបាល យ៉ាងតិច១០ឆ្នាំហើយដែលមិនមែនជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងមិនមែនជាអ្នកដឹកនាំក្នុងគណបក្សណាមួយ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាធម្មនុញ្ញ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៣៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន ០២ រូប នៃបណ្ឌិត្យសភានគរបាលកម្ពុជា ក្រសួងមហាផ្ទៃ ៖

១- លោកឧត្តមសេនីយ៍ត្រី **ប្រាក់ ភូលា** អត្តលេខ ៥៥១៥៩ ពីនាយកវិទ្យាស្ថានគ្រប់គ្រង និងបញ្ជាដឹកនាំ ទៅជាគ្រូនគរបាលជាតិកម្រិតឧត្តមថ្នាក់លេខ២ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

២- លោកឧត្តមសេនីយ៍ត្រី **ហ៊ើល ធីរិទ្ធ** អត្តលេខ ៦៧០០៦ នាយករងវិទ្យាស្ថាន ទៅជានាយកវិទ្យាស្ថានគ្រប់គ្រង និងបញ្ជាដឹកនាំ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៨៣..អនក្រ-បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់ វរនាវីឯក នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមៈ

| | | | | |
|---|---|---|---|---|
| ១-វរនាវីទោ | **ហៀល** | **សុខា** | អត្តលេខ ១៣៣២៣៩ | នាយការិយាល័យបុគ្គលិក បញ្ជាការដ្ឋានកងទ័ពជើងទឹក |
| ២-វរនាវីទោ | **ស្រ៊ី** | **ទីម** | អត្តលេខ ០១៤៩៩៤ | នាយការិយាល័យស៊ើបការ ស្នងការដ្ឋានប្រតិបត្តិការសឹក បញ្ជាការដ្ឋានកងទ័ពជើងទឹក |
| ៣-វរនាវីទោ | **សោម** | **សុវណ្ណា** | អត្តលេខ ០១០២៦៦ | នាយសេនាធិការរង មូលដ្ឋានសមុទ្រ |
| ៤-វរនាវីទោ | **ពៅ** | **ស៊ីថាន់** | អត្តលេខ ០១៥៦៩៩ | ជំនួយការ ឯកឧត្តម ស្រ៊ុន សារឿន |
| ៥-វរនាវីទោ | **ខួន** | **ឧត្តម** | អត្តលេខ ០៦៣១៦៦ | ជំនួយការ ឯកឧត្តម អគ្គលេខាធិការ អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ |

| | | | |
|---|---|---|---|
| ៦-វរនាវីទោ | **យ៉ែម សល** | អត្តលេខ ១៣៦២០៤ | ជំនួយការ ឯកឧត្តម មេបញ្ជាការ បញ្ជាការដ្ឋានកងទ័ពជើងទឹក |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

### សម្រេច

**មាត្រា១ :** តែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម៖

១-ឧត្តមសេនីយ៍ទោ **អ៊ិត ឌី** អត្តលេខ ០០០៥៤៩ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

២-ឧត្តមសេនីយ៍ទោ **ជេត សាម៉េត** អត្តលេខ ០០២៥៦៧ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៣-ឧត្តមសេនីយ៍ទោ **យង់ សារិន** អត្តលេខ ០០២៦៤៩ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
| | | 61123 | សោហ៊ុយស្នាក់នៅ | 29.500.000 | 29.500.000 | 29.500.000 | 0,0 | 7.375.000 | 100,0% |

| ជំពូក | គណនី | អនុគណនី | រាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន១ជំពូកផ្សិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4=2-3 | 5=3/4ជុំ | 6=3/2 |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | **165.500.000** | **165.500.000** | **165.500.000** | **0,0** | **41.375.000** | **100,0%** |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 62.700.000 | 62.700.000 | 62.700.000 | 0,0 | 15.675.000 | 100,0% |
| | | 61132 | សោហ៊ុយបេសកកម្ម | 11.800.000 | 11.800.000 | 11.800.000 | 0,0 | 2.950.000 | 100,0% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 85.400.000 | 85.400.000 | 85.400.000 | 0,0 | 21.350.000 | 100,0% |
| | | 61138 | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេសផ្សេងៗ | 5.600.000 | 5.600.000 | 5.600.000 | 0,0 | 1.400.000 | 100,0% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍ | **19.800.000** | **3.000.000** | **3.000.000** | **0,0** | **750.000** | **100,0%** |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 3.000.000 | 3.000.000 | 3.000.000 | 0,0 | 750.000 | 100,0% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 16.800.000 | 0,0 | 0,0 | 0,0 | 0,0 | 0,0% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី...ខែ...ឆ្នាំ២០១៦
ក. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង
ម៉ិញ ចានសុវណ្ណអាទិច្ចាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី..22 ខែ..04 ឆ្នាំ..2016
អគ្គនាយក
ជ. អគ្គនាយកដ្ឋានថវិកា
គីម ចំរើន

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី..១១..ខែមេសា ឆ្នាំ២០១៦
អគ្គនាយក
គណៈកម្មការមូលបត្រកម្ពុជា
ស៊ូ សុជាតិ

ថ្ងៃទី..១១..ខែមេសា ឆ្នាំ២០១៦
រដ្ឋទេយ្យករបុរេប្រទាន
អ៊ឹង ចន្ថា

បានឃើញ និងឯកភាព
ថ្ងៃទី១៧ ខែ... ឆ្នាំ២០១៦
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អូន ព័ន្ធមុនីរ័ត្ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible]......សហវ.ប្រ.ក

# ប្រកាសរួម
## ស្តីពី
## ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែង ទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹង បទល្មើសគ្រឿងញៀន

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សម្រេច

### ប្រការ១.-

ប្រកាសនេះមានគោលបំណងកំណត់យន្តការ ដើម្បីធានាប្រសិទ្ធភាពនៃការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

### ប្រការ២.-

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូសវត្ថុតាងពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន តទៅហៅថា "ទ្រព្យសម្បត្តិរឹបអូស" រួមមាន ៖

១. ចលនទ្រព្យ

-បរិក្ខារផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យបច្ចេកទេសផ្សេងៗ

-យានយន្តមធ្យោបាយធ្វើដំណើរ និងគ្រឿងចក្រ

-សង្ហារឹម សម្ភារៈ

២. អចលនទ្រព្យ

- ដី
- អគារ
- ទ្រព្យសម្បត្តិដែលភ្ជាប់នឹងអគារ

៣. ទ្រព្យជារតនវត្ថុ និងទ្រព្យដទៃទៀត ដែលក្រោយពីមានសាលក្រមស្ថាពររបស់តុលាការបានបង្គាប់ជាទ្រព្យសម្បត្តិរដ្ឋ។

ដោយឡែកការចាត់ចែងគ្រឿងញៀនត្រូវអនុវត្តតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបទប្បញ្ញត្តិជាធរមាន។

### ប្រការ៣.-

ត្រូវបានបង្កើត គណៈកម្មការអន្តរក្រសួងស្ថាប័នមួយ សម្រាប់រៀបចំដំណើរការពាក់ព័ន្ធនឹងការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ បានមកពីការរឹបអូសពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន តទៅហៅថា "គណៈកម្មការ"។

**ប្រការ៤.–**

គណៈកម្មការមានសមាសភាពចូលរួម ដូចខាងក្រោម៖

| | |
|---|---|
| –តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| –តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | អនុប្រធាន |
| –តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| –តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ | សមាជិក |
| –តំណាងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |

សមាសភាពជាក់ស្តែងនៃគណៈកម្មការនេះត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គណៈកម្មការ ប្រើប្រាស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ អង្គភាពពាក់ព័ន្ធនៃក្រសួង ស្ថាប័នដូចក្នុងប្រការ ៤ នៃប្រកាសនេះជាលេខាធិការដ្ឋានតាមការចាំបាច់។

**ប្រការ៥.–**

គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការងារពាក់ព័ន្ធនឹងដំណើរការក្នុងការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ
- ធ្វើការកត់ត្រា បញ្ជីសារពើភណ្ឌ ផ្ទៀងផ្ទាត់ និងបញ្ជាក់ពីភាពត្រឹមត្រូវលើទ្រព្យសម្បត្តិរឹបអូសដែលមានការពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន
- សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលបញ្ជីទ្រព្យសម្បត្តិ និងឯកសារពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន
- ត្រូវបញ្ជូនបញ្ជីទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ទៅប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឬ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រគល់ជូន។

**ប្រការ៦.–**

គណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានតាមការចាំបាច់។ ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានមានសិទ្ធិកោះប្រជុំតាមលិខិតប្រគល់សិទ្ធិ។

ក្នុងករណីចាំបាច់ គណៈកម្មការអាចអញ្ជើញភាគីពាក់ព័ន្ធផ្សេងទៀតចូលរួមក្នុងកិច្ចប្រជុំ និងចូលរួមបំពេញការងារជាមួយគណៈកម្មការ តាមការជាក់ស្តែង។

**ប្រការ៧.–**

ក្រោយពីមានសេចក្តីសម្រេចស្ថាពររបស់សាលាជម្រះក្តី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវលើកសំណើសុំលក់ទ្រព្យសម្បត្តិរឹបអូសមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច និង ក្នុងករណីចាំបាច់ ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាល។ នីតិវិធីនៃការលក់ទ្រព្យសម្បត្តិរឹបអូស ត្រូវអនុវត្តតាម នីតិវិធីដេញថ្លៃ ឬ នីតិវិធីពិគ្រោះថ្លៃដូចមានចែងក្នុងប្រកាសរួមនេះ។

**ប្រការ៨.–**

ក្រោយទទួលបានគោលការណ៍ គណៈកម្មការត្រូវធ្វើការសិក្សា វាយតម្លៃលើទ្រព្យសម្បត្តិរឹបអូស ដើម្បី កំណត់តម្លៃមូលដ្ឋានសម្រាប់ដាក់លក់។ ការវាយតម្លៃនៃទ្រព្យសម្បត្តិរឹបអូសត្រូវផ្អែកលើមូលដ្ឋានសំខាន់ៗ ដូចខាងក្រោម៖

១. ចលនទ្រព្យជាបរិក្ខារឧស្សាហកម្ម និងបច្ចេកទេស យានយន្ត គ្រឿងចក្រ សង្ហារឹម និងឧបករណ៍ សម្ភារៈត្រូវកំណត់តាមស្ថានភាព គុណភាព និងតម្លៃនៅសល់ជាក់ស្តែង។

២. អចលនទ្រព្យ

- ទំហំដី និង អគារ តាមប្លង់ ឬការកំណត់របស់សុរិយោដី
- ទីតាំង និងស្ថានភាពដី និងលក្ខណៈ គុណភាព អាយុកាលរបស់អគារ
- តម្លៃដី និងអគារតាមទិន្នន័យតម្លៃទីផ្សារជាក់ស្តែងប្រៀបធៀបនឹងតម្លៃរបស់ក្រុមហ៊ុនអចលនទ្រព្យ

៣. ចំពោះទ្រព្យជារតនវត្ថុ និងទ្រព្យដទៃទៀតដែលគ្មានតម្លៃទីផ្សារ គណៈកម្មការត្រូវវាយតម្លៃតាម យថាប្រភេទជាក់ស្តែងនៃទ្រព្យនោះ។

គណៈកម្មការ ត្រូវរៀបចំកំណត់ហេតុស្តីពីលទ្ធផលនៃការវាយតម្លៃនេះ ដោយមានចុះហត្ថលេខាពី គ្រប់សមាជិកចូលរួម និងដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងឯកភាព។

**ប្រការ៩.–**

គណៈកម្មការ ត្រូវរៀបចំចាត់ចែងកិច្ចដំណើរការលក់ដេញថ្លៃ ទ្រព្យសម្បត្តិរឹបអូសតាមនីតិវិធីដេញថ្លៃ ជាសាធារណៈ ចាប់ពីតម្លៃមូលដ្ឋានឡើង ដោយដាក់ក្នុងស្រោមសំបុត្រ ឬផ្ទាល់មាត់ ដែលអាស្រ័យលក្ខណៈ និងវិសាលភាព នៃទ្រព្យសម្បត្តិរឹបអូស និងតាមការជ្រើសរើសរបស់គណៈកម្មការ។

មូលដ្ឋាននៃការដេញថ្លៃត្រូវកំណត់ក្នុងសៀវភៅបន្ទុក ដែលរៀបចំដោយគណៈកម្មការ និងត្រូវមានការ ឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១០.–**

សៀវភៅបន្ទុកត្រូវមានកំណត់ច្បាស់លាស់នូវចំណុចសំខាន់ជាអាទិ៍៖

- កម្មវត្ថុនៃការដេញថ្លៃ
- កាលបរិច្ឆេទ និងទីកន្លែង
- ទ្រព្យសម្បត្តិជាកម្មវត្ថុនៃការដាក់ឱ្យដេញថ្លៃ (រូបទ្រព្យ ទីកន្លែង ចំនួន ទំហំលក្ខណៈ គុណភាព។ល។)
- តម្លៃមូលដ្ឋាន

- លក្ខខណ្ឌជ្រើសរើសអ្នកចូលរួមដេញថ្លៃ
- ការកក់ប្រាក់ធានាចំនួន ១០% (ដប់ភាគរយ) នៃតម្លៃមូលដ្ឋាន
- កម្មវិធីនៃការបង់ប្រាក់
- ការប្រគល់ទទួល
- វិធីដេញថ្លៃជាសាធារណៈ (ដោយដាក់ក្នុងស្រោមសំបុត្រ ឬផ្ទាល់មាត់)
- របៀបរបប និងបទបញ្ញាក្នុងកិច្ចដំណើរការដេញថ្លៃ
- បំរាមផ្សេងៗ (ការឃុបឃិតក្នុងបំណងបង្ខូចតម្លៃ ។ល។)
- ការរឹបអូសប្រាក់កក់
- ការផ្ទេរសិទ្ធិចូលរួមដេញថ្លៃ

**ប្រការ១១.-**

ការផ្សព្វផ្សាយសេចក្តីជូនដំណឹងពីការដេញថ្លៃ ត្រូវធ្វើតាមរយៈវិទ្យុផ្សាយសម្លេង ទូរទស្សន៍ សារព័ត៌មាន ការបិទផ្សាយនៅតាមក្រសួង ស្ថាប័ន រាជធានី-ខេត្ត និងអង្គភាពនានា។

**ប្រការ១២.-**

គណៈកម្មការជាអ្នកដឹកនាំ ចាត់ចែងកិច្ចដំណើរការដេញថ្លៃទ្រព្យសម្បត្តិរឹបអូសតាមការកំណត់ក្នុងសៀវភៅបន្ទុក។ ការដេញថ្លៃចាប់ពីតម្លៃមូលដ្ឋានឡើងទៅ ដែលត្រូវដាក់តម្លៃចំនួនបីលើក ។ ការដាក់តម្លៃរបស់បេក្ខជន ត្រូវធ្វើឡើងដោយសម្ងាត់ និងមានចុះហត្ថលេខាដាក់ក្នុងស្រោមសំបុត្របិទជិតដែល

- លើកទី១ ចាប់ពីតម្លៃមូលដ្ឋានឡើងទៅ
- លើកទី២ ចាប់ពីតម្លៃនៃលទ្ធផលនៃការដេញថ្លៃលើកទី ១ ដែលត្រូវបង្កើន ១០% (ដប់ភាគរយ)
- លើកទី៣ ចាប់ពីតម្លៃនៃលទ្ធផលនៃការដេញថ្លៃលើកទី ២ ដែលត្រូវបង្កើន ១០% (ដប់ភាគរយ)

ក្នុងករណីការដេញថ្លៃចំនួន ០៣ លើករួចហើយ ប៉ុន្តែមិនទាន់ទទួលបានលទ្ធផលជាស្ថាពរនោះត្រូវដំណើរការដេញថ្លៃបន្តទៀតរហូតទទួលបានលទ្ធផលឈ្នះលើការដេញថ្លៃមានតែមួយ។

ករណីដំណើរការដេញថ្លៃមិនមានភាពរលូនតាមសៀវភៅបន្ទុក ឬ មានភាពមិនប្រក្រតី ដូចជាការឃុបឃិតគ្នាបង្ខូចតម្លៃ ហើយដែលមានភស្តុតាង លទ្ធផលដេញថ្លៃត្រូវទុកជាមោឃៈ។ គណៈកម្មការត្រូវរៀបចំការដេញថ្លៃសារជាថ្មី។ បន្ទាប់ពីពិនិត្យឃើញថា ការដេញថ្លៃប្រព្រឹត្តទៅដោយប្រក្រតី តម្លាភាព និងយុត្តិធម៌ នោះគណៈកម្មការត្រូវប្រកាសលទ្ធផលនៃការដេញថ្លៃ ដោយប្រកាសរូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលហ៊ានឱ្យតម្លៃខ្ពស់ជាងគេ ។

ករណីអ្នកឈ្នះការដេញថ្លៃ បោះបង់ចោលលទ្ធផលដេញថ្លៃ នោះប្រាក់កក់ចូលដេញថ្លៃត្រូវរឹបអូស។ ករណីនេះ គណៈកម្មការត្រូវចរចាជាមួយអ្នកឈ្នះការដេញថ្លៃបន្ទាប់ពីអ្នកឈ្នះទី១ ដែលបោះបង់ចោលលទ្ធផលនៃការដេញថ្លៃ។

គណៈកម្មការត្រូវរៀបចំកំណត់ហេតុស្តីពីលទ្ធផលនៃការដេញថ្លៃ ដោយមានចុះហត្ថលេខាពីគ្រប់សមាសភាពគណៈកម្មការ ដែលបានចូលរួម និងផ្តិតមេដៃរបស់អ្នកដេញថ្លៃបាន។

កំណត់ហេតុនៃការដេញថ្លៃត្រូវដាក់សុំការពិនិត្យ និងសម្រេច ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងករណីចាំបាច់ត្រូវសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាលលើលទ្ធផលនៃការដេញថ្លៃបណ្តោះអាសន្ន និងតាមនេះ លទ្ធផលដេញថ្លៃបណ្តោះអាសន្ន ត្រូវចាត់ទុកជាលទ្ធផលស្ថាពរ។

**ប្រការ១៣.–**

នីតិវិធីពិគ្រោះថ្លៃ ដើម្បីលក់ទ្រព្យសម្បត្តិរឹបអូសត្រូវផ្អែកតាមលក្ខខណ្ឌដូចខាងក្រោម៖

- មានគោលការណ៍ពីរាជរដ្ឋាភិបាលឲ្យលក់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយ
- ការដេញថ្លៃមិនទទួលបានលទ្ធផល
- មានរូបវន្តបុគ្គល ឬ នីតិបុគ្គលតែមួយដាក់ពាក្យដេញថ្លៃ
- ទ្រព្យសម្បត្តិរឹបអូសជាកម្មវត្ថុនៃការលក់ មានភ្ជាប់លក្ខខណ្ឌត្រូវដោះស្រាយដូចជា កាតព្វកិច្ចធានាទូទាត់សងបំណុលជំនួស កាតព្វកិច្ចដោះស្រាយគោលនយោបាយ ឬ កាតព្វកិច្ចមួយចំនួនទៀតដែលតម្រូវ
- ទ្រព្យសម្បត្តិរឹបអូសជាកម្មវត្ថុនៃការលក់មានលក្ខណៈពិសេស ទាមទារឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជន មានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការទទួលយក។

**ប្រការ១៤.–**

គណៈកម្មការត្រូវរៀបចំកិច្ចសន្យាលក់ជាមួយអ្នកដេញថ្លៃ ឬ អ្នកពិគ្រោះថ្លៃបាន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. លក្ខខណ្ឌនៃការទូទាត់ :

អ្នកដេញថ្លៃ ឬ អ្នកពិគ្រោះថ្លៃបានត្រូវធ្វើការបង់យ៉ាងច្រើនជាបីដំណាក់កាល ដែលដំណាក់កាលនីមួយៗត្រូវបង់យ៉ាងតិចចំនួន៣០% (សាមសិបភាគរយ)។

២. លក្ខខណ្ឌនៃការប្រគល់ទទួល:

ក. គណៈកម្មការចេញលិខិតប្រគល់ទ្រព្យសម្បត្តិរឹបអូសជាកម្មវត្ថុនៃការលក់ ជូនអ្នកដេញថ្លៃ ឬ អ្នកពិគ្រោះថ្លៃ បានក្នុងរយៈពេលមិនលើសពី ១៥ ថ្ងៃធ្វើការ បន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌនៃការទូទាត់ និងលក្ខខណ្ឌដទៃទៀតដែលគណៈកម្មការបានកំណត់ចប់ជាស្ថាពរ

ខ. អ្នកដេញថ្លៃបានត្រូវចុះហត្ថលេខា ឬ ផ្តិតមេដៃលើឯកសារពាក់ព័ន្ធ ដើម្បីបញ្ជាក់អំពីភាពស្របច្បាប់នៃការទទួលខុសត្រូវលើទ្រព្យសម្បត្តិដែលដេញបាន។

**ប្រការ១៥.–**

ចំពោះករណីលក់ចលនទ្រព្យ មធ្យោបាយដឹកជញ្ជូន គ្រឿងចក្រ និង ឧបករណ៍សម្ភារៈ បន្ទាប់ពីរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនបានចាត់ចែងការទូទាត់តម្លៃទិញ និងបំពេញកាតព្វកិច្ចនានា ដែលមានចែងនៅក្នុងសៀវភៅបន្ទុក និងកិច្ចសន្យាលក់បានចប់សព្វគ្រប់ គណៈកម្មការត្រូវប្រគល់រូបទ្រព្យទាំងនោះ ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនដើម្បីទទួលបានការកាន់កាប់តាមច្បាប់កំណត់ ។

ចំពោះករណីលក់ដី និងអគារ បន្ទាប់ពីរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនបានទូទាត់ថ្លៃទិញផ្តាច់ បំពេញកាតព្វកិច្ចចែងក្នុងសៀវភៅបន្ទុក កិច្ចសន្យាលក់រួចរាល់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចផ្ទេរដី និងអគារដែលលក់ផ្តាច់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជន ដើម្បីបំពេញបែបបទស្នើសុំសិទ្ធិកាន់កាប់តាមច្បាប់កំណត់។

**ប្រការ១៦._**

ចំណូលទាំងអស់ដែលបានពីទ្រព្យសម្បត្តិដែលរឹបអូស និងក្រោយធ្វើការចាត់ចែងតាមសេចក្តីសម្រេចស្ថាពររបស់សាលាជម្រះក្តី ត្រូវកត់ត្រាជាចំណូលថវិការដ្ឋ និងត្រូវបែងចែកតាមប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**ប្រការ១៧._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៨._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក និង ប្រធានអង្គភាពនានា ដែលស្ថិតក្រោមឱវាទ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អគ្គលេខាធិការ និងប្រធានអង្គភាពនានា ដែលស្ថិតក្រោមឱវាទ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងប្រធានអង្គភាពនានា នៃក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៦

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** |
| **ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** |
| **នាយឧត្តមសេនីយ៍. កែ_គឹមយ៉ាន** | **បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន** |

កន្លែងទទួល៖

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *សាលារាជធានី ខេត្ត*
- *ដូចប្រការ ១៨*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ប.ក

## ប្រកាសរួម
## ស្តីពី
## ការគ្រប់គ្រង និងការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីការបង្រ្កាបបទល្មើសគ្រឿងញៀន

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញសារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សម្រេច

**ប្រការ១.-**

ចំណូលដែលប្រមូលបានជាសាច់ប្រាក់ បានមកពីការចាត់ចែងទ្រព្យសម្បត្តិ ក្រោយពីមានសេចក្តីសម្រេចស្ថាពររបស់សាលាជម្រះក្តី ដែលទ្រព្យសម្បត្តិទាំងនោះត្រូវបានរឹបអូសពីបទល្មើសគ្រឿងញៀន រួមទាំងផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសគ្រឿងញៀន និងប្រាក់ដែលបានមកពីការលក់វត្ថុ ការចាត់ចែង ឬទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ត្រូវបានកត់ត្រាទាំងស្រុងជាចំណូលថវិការដ្ឋ និងត្រូវបានបែងចែកដូចខាងក្រោម ៖

ក- ចំណែកត្រូវបង់ចូលថវិកាជាតិចំនួន ២៩% (ម្ភៃប្រាំបួនភាគរយ) នៃប្រាក់ចំណូលប្រមូលបាន

ខ- ចំណែកផ្តល់ជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនចំនួន ៧០% (ចិតសិបភាគរយ) នៃប្រាក់ចំណូលប្រមូលបាន

គ- ចំណែកផ្តល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ១% (មួយភាគរយ) នៃប្រាក់ចំណូលប្រមូលបាន សម្រាប់ចំណាយឧបត្ថម្ភលើកទឹកចិត្តមន្ត្រីដែលបំពេញភារកិច្ចពាក់ព័ន្ធ។

**ប្រការ២.–**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៣.–**

ចំណែកប្រាក់ចំណូលចំនួន ៧០% (ចិតសិបភាគរយ) នៃប្រាក់ចំណូលប្រមូលបាន ដែលផ្តល់ជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវចាត់ចែងសម្រាប់ការចំណាយដូចខាងក្រោម ៖

- ផ្តល់ឱ្យអង្គការរដ្ឋ ឬ ឱ្យទៅសមាគមឯកជន ក្នុងគោលបំណងគាំទ្រការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់ ឬ ការប្រព្រឹត្តបទល្មើសពាក់ព័ន្ធគ្រឿងញៀន
- ធ្វើវិភាគទានដល់ស្ថាប័ន អង្គភាព ឬ អង្គការឯកទេសនានា ដែលធ្វើសកម្មភាពក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន ការស្រាវជ្រាវវិទ្យាសាស្ត្រ ការធ្វើពិសោធន៍គ្រឿងញៀន ការព្យាបាល និងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីភ្នាក់ងារ ឬ អង្គភាពដែលមានស្នាដៃឆ្នើមក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ព្រមទាំងមន្ត្រីដែលបំពេញភារកិច្ចក្នុងការគ្រប់គ្រង និងប្រមូលចំណូលដែលបានមកពីបទល្មើសគ្រឿងញៀន។
- ចំណាយពង្រឹងយន្តការលើការបង្ក្រាបបទល្មើសគ្រឿងញៀន។

**ប្រការ៤.–**

អនុញ្ញាតឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាត់ទុកជាមុននូវចំណែកប្រាក់ចំណូលសរុបចំនួន ៧១% (ចិតសិបមួយភាគរយ) នៃប្រាក់ចំណូលប្រមូលបាន ដែលរួមមានចំណែករបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនចំនួន ៧០% (ចិតសិបភាគរយ) នៃប្រាក់ចំណូលប្រមូលបាន និងចំណែករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃប្រាក់ចំណូលប្រមូលបាន។ ការកាត់ទុកជាមុននូវចំណែកប្រាក់ចំណូលនេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទាន សម្រាប់ចាត់ចែង និងប្រើប្រាស់ ទៅតាមការកំណត់ដែលចែងក្នុងប្រការ ១ និងប្រការ ៣ នៃប្រកាសរួមនេះ។

រាល់ការចំណាយ ត្រូវមានសក្ខីប័ត្រចំណាយត្រឹមត្រូវ និងអនុវត្តការចំណាយប្រកបដោយប្រសិទ្ធភាព តម្លាភាព និងមានគណនេយ្យភាព។

**ប្រការ៥.–**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវគ្រោងចំណូល និងចំណាយ នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួន។ គម្រោងឥណទានចំណាយប្រចាំឆ្នាំ ត្រូវគ្រោងស្មើនឹង ៧១%

(ចិតសិបមួយភាគរយ) នៃគម្រោងចំណូលប្រចាំឆ្នាំ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយប្រចាំឆ្នាំនេះ ជាកម្មវត្ថុនៃការបោះផ្សាយអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទាន(ចំណូលដែលបានកាត់ទុកជាមុន)ពីចំណូលថវិកាជាតិ។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិដូចកិច្ចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដែរ។

**ប្រការ៦.—**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវធ្វើការទូទាត់ចំណាយលើប្រាក់បុរេប្រទានពីចំណូលថវិកាជាតិ(ចំនួន ៧១%នៃប្រាក់ចំណូលប្រមូលបាន) ដោយអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

ក. ផ្នែកចំណូល

ត្រូវធ្វើសំណើសុំកត់ត្រាចំណូល និងសលាកប័ត្រចំណូលថវិកាជាតិនូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន រួចបញ្ជូនសំណើ និងសលាកប័ត្រចំណូលថវិកាជាតិ មកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល (គំរូលេខ ០១), តារាងសម្រង់សលាកប័ត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់ (គំរូលេខ ០២), តារាងស្តីពីការគណនាបែងចែកប្រាក់ចំណូល (គំរូលេខ ០៣) និងរបាយការណ៍ចំណាយលើប្រាក់បុរេប្រទាន (គំរូលេខ ០៤)។ គំរូលេខ ០១, គំរូលេខ ០២, គំរូលេខ ០៣ និងគំរូលេខ ០៤ មានជូនភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសរួមនេះ។

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

ខ. ផ្នែកចំណាយ

ត្រូវធ្វើសំណើសុំទូទាត់ចំណាយប្រាក់រង្វាន់លើកទឹកចិត្ត និងធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

សំណុំឯកសារទូទាត់ទាំងអស់ខាងលើនេះ ត្រូវបន្តបញ្ជូនទៅអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីពិនិត្យ និងចាត់ការទៅតាមនីតិវិធីហិរញ្ញវត្ថុ។

**ប្រការ៧.—**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៨.—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.—**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក និង ប្រធានអង្គភាពនានា ដែលស្ថិតក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អគ្គលេខាធិការ និងប្រធានអង្គភាពនានា ដែលស្ថិតក្រោមឱវាទ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៦

ឧបនាយករដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

នាយឧត្តមសេនីយ៍.កែ_គឹមយ៉ាន

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

<u>កន្លែងទទួល</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ ៩
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦១៨៧ សហវ.ប្រក

ក្រសួងទេសចរណ៍

## ប្រកាសរួម
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃគ្រឹះស្ថានអង្គរ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១១អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគ្រឹះស្ថានអង្គរ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៤៥អនក្រ.តត ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលគ្រឹះស្ថានអង្គរ
- បានឃើញអនុក្រឹត្យលេខ១៤៦អនក្រ.តត ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការតែងតាំងនាយកប្រតិបត្តិនៃគ្រឹះស្ថានអង្គរ
- យោងតាមការចាំបាច់របស់គ្រឹះស្ថានអង្គរ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ១.-**

ប្រកាសរួមនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគ្រឹះស្ថានអង្គរ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១១អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ ២០១៦ ស្តីពីការបង្កើតគ្រឹះស្ថានអង្គរ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ប្រការ២.-**

ប្រកាសនេះមានគោលបំណងដូចខាងក្រោម÷

-រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់គ្រឹះស្ថានអង្គរ

-រៀបចំមុខងារ និងភារកិច្ចរបស់អង្គភាពក្រោមឱវាទគ្រឹះស្ថានអង្គរ

-ធានាគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃលទ្ធផលបំពេញការងារ

ក្នុងការគ្រប់គ្រងប្រមូលចំណូលពីការលក់ប័ណ្ណចូលទស្សនារមណីយដ្ឋានអង្គរ។

**ប្រការ៣.-**

**គ្រឹះស្ថានអង្គរ** សរសេរជាអក្សរកាត់ថា **គ.ស.អ.** មានមុខងារ និងភារកិច្ច ជាអាទិ៍ដូចមានចែងនៅក្នុងមាត្រា ៣ និងមាត្រា៤ នៃអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគ្រឹះស្ថានអង្គរ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ប្រការ៤.-**

**គ.ស.អ.** មានរចនាសម្ព័ន្ធដូចខាងក្រោម÷

- អង្គភាពត្រួតពិនិត្យ
- អង្គភាពលក់ប័ណ្ណ
- អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ

អង្គភាពនីមួយៗមានផ្នែកមួយចំនួនជាចំណុះ តាមការចាំបាច់។

អង្គការលេខនៃ **គ្រឹះស្ថានអង្គរ** ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសរួមនេះ។

**ប្រការ៥.-**

- អង្គភាពនីមួយៗ នៃគ្រឹះស្ថានអង្គរ ត្រូវដឹកនាំដោយប្រធាន០១រូប និងមានអនុប្រធាន០១រូប ឬ ០២រូប ជាជំនួយការ

- ផ្នែកចំណុះអង្គភាពនីមួយៗ នៃគ្រឹះស្ថានអង្គរដឹកនាំដោយប្រធាន០១រូប និងមានអនុប្រធាន០១រូប ឬ០២រូប ជាជំនួយការ។

**ប្រការ៦**.-

មុខងារ និងភារកិច្ចរបស់អង្គភាពត្រួតពិនិត្យនៃគ្រឹះស្ថានអង្គរ មានដូចខាងក្រោម÷

- រៀបចំក្រុមត្រួតពិនិត្យប័ណ្ណនៅតាមបណ្តាច្រកផ្លូវ និងប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ
- រៀបចំក្រុមត្រួតពិនិត្យប័ណ្ណនៅតាមគោលដៅឈរជើង
- មានភារកិច្ចផ្តល់ព័ត៌មានដល់ភ្ញៀវពីការត្រួតពិនិត្យប័ណ្ណនៅតាមគោលដៅឈរជើង
- មានភារកិច្ចដោះស្រាយជាមួយភ្ញៀវលើករណី បាត់ប័ណ្ណ ប័ណ្ណខូច បន្លំប័ណ្ណ ឬករណីផ្សេងៗទៅតាមគោលការណ៍ដែលបានកំណត់
- ធ្វើការត្រួតពិនិត្យប័ណ្ណ និងចោះប័ណ្ណជាក់ស្តែងតាមលំដាប់ថ្ងៃដែលភ្ញៀវបានទិញប័ណ្ណចូលទស្សនាប្រាសាទ
- ទប់ស្កាត់ភ្ញៀវទេសចរបរទេសទាំងអស់ដែលមិនបានទិញប័ណ្ណ
- កត់ត្រារាល់ព័ត៌មានដែលក្រុមត្រួតពិនិត្យតាមច្រកចូលផ្តល់ឱ្យ និងបូកសរុបរបាយការណ៍ប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ។
- គ្រប់គ្រងសេវាបង្គន់អនាម័យ
- ត្រួតពិនិត្យ និងតាមដានការផ្តល់សេវាអនាម័យ
- រៀបចំក្រុមបច្ចេកទេសក្នុងការថែរក្សា និងជួសជុលសម្ភារៈផ្តល់សេវាអនាម័យ
- ទទួលបន្ទុកប្រមូលកាកសំណល់ពីកន្លែងផ្តល់សេវាអនាម័យទៅកន្លែងដែលបានកំណត់។

**ប្រការ៧**.-

អង្គភាពត្រួតពិនិត្យមានផ្នែកចំនួន ០៣ ស្ថិតនៅក្រោមចំណុះ ដូចខាងក្រោម÷

១- ផ្នែកត្រួតពិនិត្យទី១

២- ផ្នែកត្រួតពិនិត្យទី២

៣- ផ្នែកសេវាបង្គន់អនាម័យ។

**ប្រការ៨**.-

មុខងារ និងភារកិច្ចរបស់ផ្នែកត្រួតពិនិត្យទី១ និងទី២ ស្ថិតនៅក្រោមចំណុះអង្គភាពត្រួតពិនិត្យនៃគ្រឹះស្ថានអង្គរ មានដូចខាងក្រោម÷

- ត្រួតពិនិត្យប័ណ្ណនៅតាមបណ្តាប្រាសាទនានា និងនៅតាមគោលដៅឈរជើង
- មានភារៈកិច្ចផ្តល់ព័ត៌មានដល់ភ្ញៀវពីការត្រួតពិនិត្យប័ណ្ណនៅតាមគោលដៅឈរជើង
- ធ្វើការត្រួតពិនិត្យប័ណ្ណ និងចោះប័ណ្ណជាក់ស្តែងតាមលំដាប់ថ្ងៃដែលភ្ញៀវបានទិញប័ណ្ណចូលទស្សនាប្រាសាទ

-ទប់ស្កាត់ភ្ញៀវទេសចរបរទេសទាំងអស់ ដែលមិនបានទិញប័ណ្ណ

-កត់ត្រាព័ត៌មានតាមច្រកចូល និងបូកសរុបរបាយការណ៍ប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ។

**ប្រការ៩.-**

មុខងារនិងភារកិច្ចរបស់ផ្នែកសេវាបង្គន់អនាម័យស្ថិតនៅក្រោមចំណុះអង្គភាពត្រួតពិនិត្យនៃគ្រឹះស្ថានអង្គរ មានដូចខាងក្រោម÷

- រៀបចំគម្រោងគ្រប់គ្រងការផ្តល់សេវាបង្គន់អនាម័យ
- ត្រួតពិនិត្យ និងតាមដានការផ្តល់សេវាបង្គន់អនាម័យ
- ទទួលបន្ទុកថែទាំនិងបោសសំអាតនៅតាមគោលដៅនៃកន្លែងផ្តល់សេវាបង្គន់អនាម័យ
- ទទួលបន្ទុកជួសជុល និងថែទាំកន្លែងផ្តល់សេវាបង្គន់អនាម័យ
- ទទួលបន្ទុកប្រមូលកាកសំណល់នៅតាមកន្លែងផ្តល់សេវាបង្គន់អនាម័យ
- រៀបចំគ្រប់គ្រង និងថែទាំសម្ភារផ្តល់សេវាបង្គន់អនាម័យទាំងអស់។

**ប្រការ១០.-**

មុខងារ និងភារកិច្ចរបស់អង្គភាពលក់ប័ណ្ណនៃគ្រឹះស្ថានអង្គរ មានដូចខាងក្រោម÷

- រៀបចំ និងគ្រប់គ្រងការលក់ប័ណ្ណតាមបញ្ជរនីមួយៗ
- គ្រប់គ្រងការប្រមូលប្រាក់ គល់ប័ណ្ណ និងរបាយការណ៍លក់ប័ណ្ណតាមបញ្ជរនីមួយៗ
- ធ្វើរបាយការណ៍ពីការលក់ប័ណ្ណប្រចាំថ្ងៃ
- ផ្ទៀងផ្ទាត់តួលេខ ចំនួនប្រាក់ និងចំនួនប័ណ្ណដែលបានលក់ប្រចាំថ្ងៃ
- ធ្វើការប្រៀបធៀបរបាយការណ៍លក់និងទិន្នន័យពីកុំព្យូទ័រប្រចាំថ្ងៃ
- ប្រគល់ប្រាក់ដែលលក់បានប្រចាំថ្ងៃជូនបេឡា
- បូកសរុបរបាយការណ៍ស្តីពីការលក់ប័ណ្ណប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ។

**ប្រការ១១.-**

អង្គភាពលក់ប័ណ្ណមានផ្នែកចំនួន ០៤ ស្ថិតនៅក្រោមចំណុះ ដូចខាងក្រោម÷

១-ផ្នែកផ្តល់ព័ត៌មានទី១

២-ផ្នែកផ្តល់ព័ត៌មានទី២

៣-ផ្នែកលក់ប័ណ្ណទី១

៤-ផ្នែកលក់ប័ណ្ណទី២

**ប្រការ១២.-**

មុខងារ និងភារកិច្ចរបស់ផ្នែកផ្តល់ព័ត៌មានទី១ និងទី២ ស្ថិតនៅក្រោមចំណុះអង្គភាពលក់ប័ណ្ណនៃគ្រឹះស្ថានអង្គរ មានដូចខាងក្រោម÷

- សហការក្នុងការលក់ប័ណ្ណជាមួយក្រុមលក់ប័ណ្ណនៅតាមបញ្ជរលក់ប័ណ្ណនីមួយៗ
- រៀបចំ និងសម្រួលដល់ភ្ញៀវមកទិញប័ណ្ណនៅតាមបញ្ជរលក់ប័ណ្ណនីមួយៗ
- មានភារកិច្ចពន្យល់ភ្ញៀវ ឬផ្តល់ព័ត៌មានដល់ភ្ញៀវពីការថែរក្សាប័ណ្ណ ដើម្បីបង្ហាញប័ណ្ណដល់អ្នកត្រួតពិនិត្យនៅតាមគោលដៅត្រួតពិនិត្យ
- ដោះស្រាយជាមួយភ្ញៀវតាមគោលការណ៍ដែលបានកំណត់ ក្នុងករណីបាត់ប័ណ្ណ ឬរហែកប័ណ្ណ
- ផ្តល់ព័ត៌មានដល់ច្រកចូល រាល់បញ្ហាផ្សេងៗ ជាមុនក្នុងករណីដែលបានដោះស្រាយជាមួយភ្ញៀវ ឬសម្រួលជាមួយភ្ញៀវ
- ចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយទេសចរណ៍ បោះពុម្ពឯកសារផ្សព្វផ្សាយនានា និងផ្សព្វផ្សាយតាមគេហទំព័ររបស់គ្រឹះស្ថានអង្គរ។

**ប្រការ១៣.-**

មុខងារ និងភារកិច្ចរបស់ផ្នែកលក់ប័ណ្ណទី១ និងទី២ នៅក្រោមចំណុះអង្គភាពលក់ប័ណ្ណនៃគ្រឹះស្ថានអង្គរ មានដូចខាងក្រោម÷

- រៀបចំ និងគ្រប់គ្រងការលក់ប័ណ្ណតាមបញ្ជរនីមួយៗ
- គ្រប់គ្រងការប្រមូលប្រាក់ គល់ប័ណ្ណ និងរបាយការណ៍លក់ប័ណ្ណតាមបញ្ជរនីមួយៗ
- ធ្វើរបាយការណ៍ពីការលក់ប័ណ្ណប្រចាំថ្ងៃ
- ផ្ទៀងផ្ទាត់តួលេខ ចំនួនប្រាក់ និងចំនួនប័ណ្ណដែលបានលក់ប្រចាំថ្ងៃ
- ធ្វើការប្រៀបធៀបរបាយការណ៍លក់និងទិន្នន័យពីកុំព្យូទ័រប្រចាំថ្ងៃ
- ប្រគល់ប្រាក់ដែលលក់បានប្រចាំថ្ងៃជូនបេឡា
- បូកសរុបរបាយការណ៍ស្តីពីការលក់ប័ណ្ណប្រចាំថ្ងៃប្រចាំខែ និងប្រចាំឆ្នាំ។

**ប្រការ១៤.-**

មុខងារនិងភារកិច្ចរបស់អង្គភាពរដ្ឋបាលនិងហិរញ្ញវត្ថុនៃគ្រឹះស្ថានអង្គរ មានដូចខាងក្រោម÷

- រៀបចំបញ្ជីបុគ្គលិក និងបញ្ជីប្រាក់បៀវត្សរ៍បុគ្គលិក មន្ត្រីរាជការប្រចាំខែ
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថាន
- គ្រប់គ្រងការប្រមូលប្រាក់ និងបង់ចូលធនាគារតាមកាលកំណត់
- លើកសំណើសុំលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិកគ្រប់ប្រភេទ
- គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថាន

- រៀបចំផែនការបណ្តុះបណ្តាល និងគ្រប់គ្រងបុគ្គលិក
- ទទួលបន្ទុកផ្តល់ព័ត៌មាន និងទំនាក់ទំនងសាធារណៈ
- ទទួលបន្ទុកដោះស្រាយវិវាទជាមួយភ្ញៀវ
- រៀបចំរបាយការណ៍នៃការគ្រប់គ្រងបុគ្គលិក របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងរបាយការណ៍លទ្ធកម្មរបស់គ្រឹះស្ថាន។
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**ប្រការ១៥.-**

អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ មានផ្នែកចំនួន ២ស្ថិតនៅក្រោមចំណុះ ដូចខាងក្រោម÷

១-ផ្នែករដ្ឋបាល និងបុគ្គលិក

២-ផ្នែកគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ។

**ប្រការ១៦.-**

មុខងារនិងភារកិច្ចរបស់ផ្នែករដ្ឋបាលនិងបុគ្គលិកស្ថិតនៅក្រោមចំណុះអង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុនៃគ្រឹះស្ថានអង្គរ មានដូចខាងក្រោម÷

- រៀបចំបញ្ជីប្រាក់បៀវត្សបុគ្គលិកប្រចាំខែ
- រៀបចំលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិក មន្ត្រីរាជការគ្រប់ប្រភេទ
- រៀបចំផែនការបណ្តុះបណ្តាល គ្រប់គ្រងបុគ្គលិក និងជ្រើសរើសបុគ្គលិក
- ទទួលបន្ទុកផ្តល់ព័ត៌មាន និងទំនាក់ទំនងសាធារណៈ
- ទទួលបន្ទុកដោះស្រាយវិវាទជាមួយភ្ញៀវ
- ការងារវាយតម្លៃបុគ្គលិក
- រៀបចំរបាយការណ៍នៃការគ្រប់គ្រងបុគ្គលិក។

**ប្រការ១៧.-**

មុខងារនិងភារកិច្ចរបស់ផ្នែកគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋស្ថិតនៅក្រោមចំណុះអង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុនៃគ្រឹះស្ថានអង្គរ មានដូចខាងក្រោម÷

- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថាន
- គ្រប់គ្រងការប្រមូលប្រាក់ និងបង់ចូលធនាគារតាមកាលកំណត់
- លើកសំណើសុំលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិក មន្ត្រីរាជការគ្រប់ប្រភេទ
- គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ

- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថាន
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងរបាយការណ៍លទ្ធកម្មរបស់គ្រឹះស្ថាន
- រៀបចំផែនការចំណូលប្រចាំឆ្នាំរបស់គ្រឹះស្ថាន
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមគោលការណ៍ជាធរមាន។

**ប្រការ១៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៩.-**

នាយកប្រតិបត្តិ ប្រធានអង្គភាព ប្រធានផ្នែក និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទាំងអស់ដែលកំពុងបម្រើការនៅ គ.ស.អ. ត្រូវអនុវត្តប្រកាសរួមនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងទេសចរណ៍**

**ថោង ខុន**

**<u>កន្លែងទទួល:</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងទេសចរណ៍
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ក្រុមប្រឹក្សាភិបាលគ្រឹះស្ថានអង្គរ
-សាលាខេត្តសៀមរាប
-ដូចប្រការ (១៩)
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..៦២៥.......សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការបង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០១៦
# របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ខែធ្នូឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ចុះថ្ងៃទី១៣ខែឧសភាឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៧អនក្រ.បក ចុះថ្ងៃទី២០ខែសីហាឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៨១អនក្រ.បក ចុះថ្ងៃទី១៦ខែវិច្ឆិកាឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួងខេត្តក្រុងក្រុងស្វយ័តរាជធានីភ្នំពេញនិងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ០០៤សហវ.ម.ប្រក ចុះថ្ងៃទី១៥ខែមករាឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៨៩សហវ.ប្រក ចុះថ្ងៃទី២២ខែកុម្ភៈឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃ មាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ២១១សហវ.ប្រក ចុះថ្ងៃទី០៤ខែមីនាឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ខែធ្នូឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដាឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ ៤ ប្រការ ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ខែធ្នូឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ១៦២អយក.ប្រក ចុះថ្ងៃទី០២ខែកុម្ភៈឆ្នាំ២០១៥ ស្តីពីការដាក់អោយអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ" និង ជំពូក៦១ "សេវាកម្ម"នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់មុខសញ្ញាចំណាយ ដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដាឆ្នាំ២០១៥ ស្តីពីការកែសម្រួល ប្រការ ៤ ប្រការ ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ខែធ្នូឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។ ចំនួនទឹកប្រាក់អតិបរមានៃចំណាយដែលអនុញ្ញាតអោយរជ្ជទេយ្យករបុរេប្រទានធ្វើការទូទាត់ត្រូវកំណត់ក្នុងមួយប័ណ្ណចំណាយ អាចលើសពី ៥.០០០.០០០ រៀល (ប្រាំលានរៀលគត់) ទៅតាមចំណាត់ថ្នាក់ចំណាយ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយ ប្រកាសអន្តរក្រសួង។

**ប្រការ២.-**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទានត្រូវកំណត់ដូចក្នុង តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ព្រមទាំងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**ប្រាក់_សុខុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធីតាមចំណាត់ថ្នាក់សេដ្ឋកិច្ចឆ្នាំ២០១៦

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានខ្ទាត់ត្រង់ | ឥណទាន០១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ជុំ | ៦=៣/២ |
| | | | សរុបរួម | 62,575,000,000 | 39,595,400,000 | 6,861,000,000 | 32,734,400,000 | 1,715,250,000 | 17% |
| 60 | | | ការទិញ | 9,333,000,000 | 3,903,000,000 | 868,000,000 | 3,035,000,000 | 217,000,000 | 22% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 2,178,000,000 | 523,000,000 | 210,000,000 | 313,000,000 | 52,500,000 | 40% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 403,000,000 | 403,000,000 | 130,000,000 | 273,000,000 | 32,500,000 | 32% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 80,000,000 | 80,000,000 | 40,000,000 | 40,000,000 | 10,000,000 | 50% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 1,655,000,000 | | | | | |
| | | 60018 | សម្ភារៈផ្គត់ផ្គង់ថែទាំផ្សេងៗ | 40,000,000 | 40,000,000 | 40,000,000 | 0 | 10,000,000 | 100% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 1,811,000,000 | 1,811,000,000 | 398,000,000 | 1,413,000,000 | 99,500,000 | 22% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 1,751,000,000 | 1,751,000,000 | 378,000,000 | 1,373,000,000 | 94,500,000 | 22% |
| | | 60022 | សៀវភៅមើលនិងឯកសារ | 60,000,000 | 60,000,000 | 20,000,000 | 40,000,000 | 5,000,000 | 33% |
| | 6004 | | សំលៀកបំពាក់និងការតុបតែង | 112,000,000 | 112,000,000 | 57,000,000 | 55,000,000 | 14,250,000 | 51% |
| | | 60041 | ឯកសណ្ឋាន | 112,000,000 | 112,000,000 | 57,000,000 | 55,000,000 | 14,250,000 | 51% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសមហភារៈបរិក្ខារ | 2,021,000,000 | 1,457,000,000 | 203,000,000 | 1,254,000,000 | 50,750,000 | 14% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 776,000,000 | 776,000,000 | 80,000,000 | 696,000,000 | 20,000,000 | 10% |
| | | 60052 | សង្ហារឹម | 314,000,000 | 314,000,000 | 58,000,000 | 256,000,000 | 14,500,000 | 18% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 367,000,000 | 367,000,000 | 65,000,000 | 302,000,000 | 16,250,000 | 18% |
| | | 60054 | សម្ភារៈនិងឧបករណ៍ដឹកជញ្ជូន | 522,000,000 | | | | | |
| | | 60058 | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារផ្សេងៗ | 42,000,000 | | | | | |
| | 6006 | | ថាមពលនិងទឹក | 3,211,000,000 | | | | | |
| | | 60061 | អគ្គីសនី | 2,278,000,000 | | | | | |
| | | 60062 | ទឹក | 733,000,000 | | | | | |
| | | 60068 | ផ្សេងៗ | 200,000,000 | | | | | |
| 61 | | | សេវាកម្ម | 53,242,000,000 | 35,692,400,000 | 5,993,000,000 | 29,699,400,000 | 1,498,250,000 | 17% |
| | 6101 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស | 400,000,000 | | | | | |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 1,302,000,000 | 1,302,000,000 | 20,000,000 | 1,282,000,000 | 5,000,000 | 2% |
| | 6103 | | ថ្លៃឈ្នួលនិងបន្ទុក(អសង្ហារឹម) | 10,089,600,000 | | | | | |
| | 6105 | | ការថែទាំនិងជួសជុល | 8,937,000,000 | 8,937,000,000 | 500,000,000 | 8,437,000,000 | 125,000,000 | 6% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗនិងប្រាសាទ | 4,094,000,000 | 4,094,000,000 | 80,000,000 | 4,014,000,000 | 20,000,000 | 2% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 1,096,000,000 | 1,096,000,000 | 130,000,000 | 966,000,000 | 32,500,000 | 12% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 2,271,000,000 | 2,271,000,000 | 90,000,000 | 2,181,000,000 | 22,500,000 | 4% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈនិងឧបករណ៍បច្ចេកទេស | 1,476,000,000 | 1,476,000,000 | 200,000,000 | 1,276,000,000 | 50,000,000 | 14% |
| | 6106 | | សោហ៊ុយធានារ៉ាប់រង | 1,204,000,000 | | | | | |
| | 6108 | | សោហ៊ុយដឹកជញ្ជូន | 314,000,000 | | | | | |
| | | 61081 | សម្ភារៈនិងទំនិញ | 314,000,000 | | | | | |
| | 6109 | | បុគ្គលិកខាងក្រៅ | 5,006,000,000 | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61092 | ភ្នាក់ងារបរទេសជាប់កិច្ចសន្យា | 5,006,000,000 | | | | | |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 10,420,200,000 | 10,420,200,000 | 1,059,000,000 | 9,361,200,000 | 264,750,000 | 10% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 1,007,000,000 | 1,007,000,000 | 120,000,000 | 887,000,000 | 30,000,000 | 12% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 4,218,000,000 | 4,218,000,000 | 500,000,000 | 3,718,000,000 | 125,000,000 | 12% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 3,421,000,000 | 3,421,000,000 | 200,000,000 | 3,221,000,000 | 50,000,000 | 6% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 914,000,000 | 914,000,000 | 69,000,000 | 845,000,000 | 17,250,000 | 8% |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍នៅក្នុងនិងក្រៅប្រទេស | 714,200,000 | 714,200,000 | 100,000,000 | 614,200,000 | 25,000,000 | 14% |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 146,000,000 | 146,000,000 | 70,000,000 | 76,000,000 | 17,500,000 | 48% |
| | 6111 | | ចំណាយលើការជាវសារព័ត៌មាននិងឯកសារ | 352,000,000 | | | | | |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 146,000,000 | | | | | |
| | | 61113 | ចំណាយលើការជាវសៀវភៅរាជកិច្ច | 20,000,000 | | | | | |
| | | 61118 | ចំណាយលើការជាវសារព័ត៌មាននិងឯកសារផ្សេងៗ | 186,000,000 | | | | | |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 854,000,000 | 854,000,000 | 854,000,000 | 0 | 213,500,000 | 100% |
| | | 61121 | សោហ៊ុយដឹកជញ្ជូនក្នុងប្រទេស | 444,000,000 | 444,000,000 | 444,000,000 | 0 | 111,000,000 | 100% |
| | | 61122 | សោហ៊ុយបេសកកម្មក្នុងប្រទេស | 170,000,000 | 170,000,000 | 170,000,000 | 0 | 42,500,000 | 100% |
| | | 61123 | សោហ៊ុយស្នាក់នៅក្នុងប្រទេស | 200,000,000 | 200,000,000 | 200,000,000 | 0 | 50,000,000 | 100% |
| | | 61128 | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេសផ្សេងៗ | 40,000,000 | 40,000,000 | 40,000,000 | 0 | 10,000,000 | 100% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 12,312,800,000 | 12,302,800,000 | 3,470,000,000 | 8,832,800,000 | 867,500,000 | 28% |
